# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចសហប្រតិបត្តិការរវាង
# អគ្គលេខាធិការដ្ឋានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
# និង វិទ្យាស្ថានចក្ខុវិស័យអាស៊ី

កាលពីព្រឹក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) បានប្រារព្ធពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា នៅរដ្ឋសភាជាតិកម្ពុជា។ ពិធីចុះហត្ថលេខានេះ ត្រូវបានប្រារព្ធឡើងក្រោមអធិបតីភាព **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** អនុប្រធានទី២ នៃរដ្ឋសភា **ឯកឧត្តម ឡេង ប៉េងឡុង** អគ្គលេខាធិការនៃរដ្ឋសភា **ឯកឧត្តមបណ្ឌិត សុក ស៊ីផាន់ណា** ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានចក្ខុវិស័យអាស៊ី **ឯកឧត្តម សួស យ៉ារ៉ា** អគ្គនាយកក្រុមប្រឹក្សាវប្បធម៌អាស៊ី **លោកបណ្ឌិត ឈាង វណ្ណារិទ្ធ** ប្រធានវិទ្យាស្ថានចក្ខុវិស័យអាស៊ី **លោកបណ្ឌិត កែវ ពិសិដ្ឋ** អនុប្រធានវិទ្យាស្ថានចក្ខុវិស័យអាស៊ី **លោកបណ្ឌិត ឆេង គីមឡុង** អនុប្រធានវិទ្យាស្ថានចក្ខុវិស័យអាស៊ី និងលោក លោកស្រី ដែលជាសមាជិកសមាជិកានៃស្ថាប័នទាំងពីរ។

ការចុះអនុស្សារណៈយោគយល់គ្នានេះ មានគោលបំណងបង្កើត និងលើកកម្ពស់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ ក្នុងវិស័យ សិក្សា ស្រាវជ្រាវ ការរៀបចំសិក្ខាសាលារួម ការផ្សព្វផ្សាយនិងទំនាក់ទំនងសាធារណៈ រួមទាំងការពិគ្រោះយោបល់អំពីកិច្ចការជាតិ និងអន្តរជាតិនានា។

ស្របពេលដែលកម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលសភាអាស៊ីអឺរ៉ុប លើកទី១១ ក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអន្តរសភាអាស៊ាន(AIPA) នៅឆ្នាំ២០២២ ខាងមុខនេះ ព្រមទាំងជាម្ចាស់ផ្ទះអាស៊ាននាឆ្នាំក្រោយផងដែរនោះ ការចុះអនុស្សារណៈយោគយល់គ្នារវាងស្ថាប័នទាំងពីរនេះគឺពិតជាឱកាសដ៏ល្អ និងសមស្របមួយ ដែលអនុញ្ញាតឱ្យស្ថាប័នទាំងពីរសហការគ្នាដើម្បីគាំទ្រដល់តួនាទីរបស់កម្ពុជា និងធានាឱ្យបាននូវសមិទ្ធផលផ្លែផ្កា ក៏ដូចជាវឌ្ឍនភាពសម្រាប់កម្ពុជា តំបន់ និងពិភពលោកទាំងមូលផងដែរ។

**លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** បានមានប្រសាសន៍ប្រកបដោយភាពសុទិដ្ឋិនិយមថា «កិច្ចសហប្រតិបត្តិការរវាងរដ្ឋសភា និងវិទ្យាស្ថានចក្ខុវិស័យអាស៊ីនេះ នឹងនាំមកនូវផលប្រយោជន៍ជាច្រើនដល់ប្រទេសជាតិ និងប្រជាជនយើង»។ **លោកជំទាវកិត្តិសង្គហបណ្ឌិត** បានបន្ថែមទៀតថា «ការចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នានៅថ្ងៃនេះ គឺជាសក្ខីភាពនៃទំនុកចិត្តរបស់រដ្ឋសភាជាតិលើតួនាទីដ៏សំខាន់របស់វិទ្យាស្ថានចក្ខុវិស័យអាស៊ី ក្នុងការចូលរួមចំណែកដល់ការ

សម្រេចឲ្យបាននូវបេសកកម្មចំបង ដែលរដ្ឋសភាបាននិងកំពុងបំពេញ»។ ជាមួយគ្នានេះ **លោកជំទាវកិត្តិសង្គហបណ្ឌិត** ក៏បានរំលឹកឡើងវិញផងដែរនូវការចូលរួមចំណែកយ៉ាងសកម្មជាច្រើនរបស់ក្រុមការងារ AVI នាពេលកន្លងមក ដើម្បីជួយដល់កិច្ចការងារសំខាន់ៗរបស់រដ្ឋសភាជាតិនៅលើឆាកអន្តរជាតិ ដែលមានដូចជា វេទិកាសភាអាស៊ីប៉ាស៊ីហ្វិក (APPF) កិច្ចប្រជុំកំពូលសភាអាស៊ីអឺរ៉ុបលើកទី១១ (ASEP១១) សន្និសីទនៃគណៈកម្មការកិច្ចការបរទេសនៃសភាកម្ពុជា-ឡាវ-វៀតណាម (CLV-DTA) និងកិច្ចប្រជុំអន្តរសភាអាស៊ាន (AIPA) ជាដើម។

**ឯកឧត្តម ឡេង ប៉េងឡុង** បានចាត់ទុកអនុស្សារណៈយោគយល់គ្នារវាងស្ថាប័នទាំងពីរនេះ ជាកិច្ចសហប្រតិបត្តិការដ៏សំខាន់មួយ ដែលអាចជួយជំរុញឱ្យរដ្ឋសភាជាតិបង្កើនគុណភាពការងាររបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពទាំងក្នុងការងារជាតិ និងអន្តរជាតិ។ **ឯកឧត្តម** បានបន្ថែមទៀតថា តាមរយៈកិច្ចសហប្រតិបត្តិការនេះ វិទ្យាស្ថានចក្ខុវិស័យអាស៊ីនឹងចូលរួមចំណែកក្នុងការលើកកម្ពស់វិស័យការទូតសភា នៅក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្ម ៤.០ ដ៏ឿនលឿននេះ។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានចក្ខុវិស័យអាស៊ី **ឯកឧត្តមបណ្ឌិត សុក ស៊ីផាន់ណា** បានលើកឡើងថា «ប្រឹត្បិតតែ AVI មានអាយុក្មេងខ្ចីក៏ដោយក្តី ស្ថាប័ននេះបានបង្កើតកេរ្តិ៍ឈ្មោះរបស់ខ្លួនយ៉ាងឆាប់រហ័សទាំងក្នុង និងក្រៅប្រទេស»។ **ឯកឧត្តមបណ្ឌិត** ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំរដ្ឋសភាដែលបានផ្តល់នូវទំនុកចិត្ត និងភាពជឿជាក់មកលើ AVI។ **ឯកឧត្តមបណ្ឌិត** ក៏បានកោតសរសើរដល់សហការីរបស់ AVI នូវកិច្ចខិតខំប្រឹងប្រែងប្រកបដោយភាពស្មោះត្រង់ និងស្មារតីបម្រើជាតិ នាពេលកន្លងមក ផងដែរ។

ជាចុងក្រោយ ភាគីទាំងពីរបានបង្ហាញនូវការតាំងចិត្តរបស់ខ្លួនក្នុងការសហការគ្នាឱ្យកាន់តែមានភាពជិតស្និទ្ធ ដើម្បីអនុវត្តការងារស្របទៅតាមគោលបំណង និងវិសាលភាពដែលត្រូវបានព្រមព្រៀងគ្នានៅក្នុងអនុស្សារណៈយោគយល់គ្នានេះ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១

**នាយកដ្ឋានកិច្ចការបង្ហាញវិទ្យាស្ថានចក្ខុវិស័យអាស៊ី**